# *របាយការណ៍ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលថ្នាក់ជាតិ*

# *ប្រចាំខែសីហា ឆ្នាំ ២០១៨*

*(បណ្ដោះអាសន្ន)*

**មាតិកា** **ទំព័រ**


| | |
|---|---|
| ១.សេចក្ដីសង្ខេប | ១ |
| ២.តារាងស្ថិតិ | |
| ២.១.ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល | ២ |
| ២.២.តារាងស្ថិតិចំណូល | ៣ |
| ២.៣.តារាងស្ថិតិចំណាយ | ៥ |
| ២.៤.តារាងស្ថិតិបម្រែបម្រួលទ្រព្យសកម្ម/បំណុល | ៦ |
| ៣.ក្រាហ្វិក | ៧ |
| ៤.ឧបសម្ព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | ៩ |
| ៥.សេចក្ដីសង្ខេបអំពី "ក្របខ័ណ្ឌស្តង់ដារស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល" | ១០ |

## ១.សេចក្តីសង្ខេប

## ស្តីពីការអនុវត្តថវិកា ខែសីហា ឆ្នាំ ២០១៨

1. **ការអនុវត្តចំណូល÷** ក្នុងខែសីហា ឆ្នាំ២០១៨នេះ ចំណូលរដ្ឋបាលថ្នាក់ជាតិអនុវត្តបាន ១ ៦៨៤ ៥៧១ លានរៀលគឺបានកើនឡើង ១៣,៥៣% ឬស្មើនឹង ២០០ ៧៩៧ លានរៀល បើធៀបនឹងខែសីហាឆ្នាំ២០១៧។ ក្នុងរយៈពេល៨ខែ ឆ្នាំ២០១៨នេះ ចំណូលរដ្ឋបាលថ្នាក់ជាតិសរុបអនុវត្តបាន ១២ ៨៦៥ ៥១២ លានរៀលឬស្មើនឹង ៧១,៣៧% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨ ឬបានកើនឡើង ៦,៤២% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧។ ចំណូលនេះត្រូវបានគាំទ្រដោយ ចំណូលពន្ធប្រមាណ ៨៥,១៣% ចំណូលផ្សេងៗនិងចំណូលពីអំណោយប្រមាណ ១៤,៨៧%។

2. **ចំណាយសរុប÷** ក្នុងខែសីហា ឆ្នាំ២០១៨នេះ ចំណាយសរុបរដ្ឋបាលថ្នាក់ជាតិអនុវត្តបាន ១ ៩០៩ ៦៣១ លានរៀល គឺបានកើនឡើង ៣០,៥៨% ឬស្មើនឹង ៤៤៧ ២៤១ លានរៀល បើធៀបទៅនឹងខែសីហាឆ្នាំ២០១៧។ ក្នុងរយៈពេល៨ខែ ឆ្នាំ២០១៨នេះ ចំណាយសរុបអនុវត្តបាន ១១ ៨៥៤ ៥៤៦ លានរៀល ឬស្មើនឹង ៥៣,៨៥% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨ បានកើនឡើង ១២,៧១% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧។ ក្នុងចំណាយសរុបនេះ រួមមាន**ចំណាយ** (expense) សម្រេចបាន ៥៨,៨៥% និង**ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ** (net acquisition of non-financial assets) សម្រេចបាន ៤៤,៨៤% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨។

3. **តុល្យភាពប្រតិបត្តិការដុល** (ចំណូលដកចំណាយ)÷ គិតត្រឹមខែសីហាឆ្នាំ២០១៨នេះ តុល្យភាពប្រតិបត្តិការដុលមានសមតុល្យចំនួន ៤ ៥០៣ ២៣២ លានរៀលឬបាន**ថយចុះ** ៨,៤៦% បើធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧។ ចំណែកឯ **សមតុល្យនៃការឲ្យខ្ចី/ខ្ចីសុទ្ធ** (ចំណូលដកចំណាយសរុប) គិតត្រឹមខែសីហាឆ្នាំ២០១៨នេះ មានសមតុល្យចំនួន ១ ០១០ ៩៦៦ លានរៀល ដែលក្នុងនោះមានទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធសរុបចំនួន ១ ៦០៣ ៥១៤ លានរៀល និងបំណុលសរុបបានកើនឡើងចំនួន ៥៩២ ៥០៥ លានរៀល។

4. **សន្និដ្ឋាន÷** សម្រាប់ខែសីហាឆ្នាំ២០១៨នេះ ការអនុវត្តថវិកាទទួលបានលទ្ធផលល្អប្រសើរ ដោយការប្រមូលចំណូលបានកើនឡើង ១៣,៥៣% ការអនុវត្តចំណាយបានខ្ពស់ជាង ១០,៦៦% និងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុបានកើនឡើង ៩២,៤៤% បើធៀបទៅនឹងខែសីហាឆ្នាំ២០១៧។ ជាងនេះទៅទៀត ក្នុងរយៈពេល៨ខែឆ្នាំ២០១៨នេះ ការអនុវត្តថវិការដ្ឋបាលថ្នាក់ជាតិ ក៏មានភាពល្អប្រសើរដែលបានបង្ហាញតាមរយៈចំណូលកើនឡើងប្រមាណ ៦,៤២% ចំណាយបានកើនឡើង ១៦,៦៣% និងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុបានកើនឡើង ៤,៣១% រៀងគ្នាស្របពេលដែលបំណុលកើនឡើងសុទ្ធបានថយចុះ ២៦,១១% បើធៀបនឹងការអនុវត្តក្នុងរយៈពេលដូចគ្នានាឆ្នាំ២០១៧។ ជាមួយគ្នានេះ ថវិការដ្ឋបាលថ្នាក់ជាតិបានរក្សានូវតុល្យភាពប្រតិបត្តិការដុលសរុបចំនួន ៤ ៥០៣ ២៣២ លានរៀល ឬស្មើនឹង ៣,៦៧ដង នៃចំណាយក្នុងខែសីហាឆ្នាំ២០១៨។

# ២.១. ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល

ឯកតា÷ លានរៀល

| | | ច្បាប់ឆ្នាំ ២០១៨ | អនុវត្តន៍ ២០១៨ | អនុ/ច្ប ២០១៨ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភៈ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីសាស្រ្តគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| **1** | **ចំណូល** | **18,026,105.0** | **12,865,511.6** | **71.37%** | **1,291,345.8** | **1,340,361.1** | **1,805,687.4** | **1,989,357.7** | **1,720,455.6** | **1,562,942.6** | **1,470,790.0** | **1,684,571.4** | **0.0** | **0.0** | **0.0** | **0.0** |
| 11 | ពន្ធ | 14,814,568.0 | 10,952,974.3 | 73.93% | 1,120,259.9 | 1,140,239.1 | 1,653,275.1 | 1,604,796.2 | 1,423,042.7 | 1,360,855.9 | 1,178,491.5 | 1,472,013.8 | 0.0 | 0.0 | 0.0 | 0.0 |
| 13 | អំណោយ | 716,102.0 | 538,627.0 | 75.22% | 49,258.5 | 49,258.5 | 58,224.8 | 72,131.9 | 150,755.6 | 60,270.6 | 49,258.5 | 49,468.6 | ... | ... | ... | ... |
| 14 | ចំណូលផ្សេងៗ | 2,495,435.0 | 1,373,910.3 | 55.06% | 121,827.4 | 150,863.5 | 94,187.5 | 312,429.6 | 146,657.3 | 141,816.0 | 243,040.0 | 163,089.0 | ... | ... | ... | ... |
| **2** | **ចំណាយ** | **14,209,516.0** | **8,362,279.8** | **58.85%** | **598,763.3** | **991,699.9** | **1,016,607.3** | **928,359.0** | **1,127,955.2** | **1,089,574.0** | **1,385,338.2** | **1,223,983.0** | **...** | **...** | **...** | **...** |
| 21 | បន្ទុកបុគ្គលិក | 7,002,828.9 | 4,459,884.3 | 63.69% | 457,742.4 | 499,001.0 | 567,747.9 | 531,646.2 | 570,046.3 | 605,655.7 | 647,725.3 | 580,319.5 | ... | ... | ... | ... |
| 22 | ទំនិញ និងសេវាកម្ម | 3,122,211.4 | 1,306,058.4 | 41.83% | 42,110.0 | 39,564.2 | 78,300.7 | 133,807.8 | 224,856.7 | 170,519.7 | 288,392.1 | 328,507.2 | ... | ... | ... | ... |
| 24 | ការប្រាក់ | 387,481.0 | 281,518.6 | 72.65% | 26,400.5 | 57,738.6 | 57,697.5 | 11,758.8 | 13,953.2 | 3,081.8 | 27,096.6 | 83,791.6 | ... | ... | ... | ... |
| 25 | ឧបត្ថម្ភកធន | 10,920.0 | 10,484.7 | 96.01% | 0.0 | 0.0 | 0.0 | 0.0 | 5,206.7 | 0.0 | 5,278.0 | 0.0 | ... | ... | ... | ... |
| 26 | អំណោយ | 1,217,274.4 | 922,494.8 | 75.78% | 991.9 | 298,149.7 | 52,122.5 | 174,505.9 | 50,276.2 | 32,773.3 | 203,541.7 | 110,133.7 | ... | ... | ... | ... |
| 27 | ឧបត្ថម្ភសង្គមកិច្ច | 1,484,210.5 | 949,832.5 | 64.00% | 62,800.5 | 78,463.1 | 132,842.3 | 49,262.2 | 222,644.5 | 158,456.4 | 162,328.0 | 83,035.5 | ... | ... | ... | ... |
| 28 | ចំណាយផ្សេងៗ | 984,589.8 | 432,006.6 | 43.88% | 8,718.0 | 18,783.3 | 127,896.4 | 27,378.1 | 40,971.6 | 119,087.2 | 50,976.5 | 38,195.5 | ... | ... | ... | ... |
| ***GOB*** | ***តុល្យភាពប្រតិបត្តិការដុល*** | **3,816,589.0** | **4,503,231.8** | **117.99%** | **692,582.5** | **348,661.2** | **789,080.2** | **1,060,998.7** | **592,500.4** | **473,368.6** | **85,451.8** | **460,588.4** | **0.0** | **0.0** | **0.0** | **0.0** |
| ***NOB*** | ***តុល្យភាពប្រតិបត្តិការសុទ្ធ*** | **3,816,589.0** | **4,503,231.8** | **117.99%** | **692,582.5** | **348,661.2** | **789,080.2** | **1,060,998.7** | **592,500.4** | **473,368.6** | **85,451.8** | **460,588.4** | **0.0** | **0.0** | **0.0** | **0.0** |
| **31** | **ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ** | 7,787,598.1 | 3,492,265.8 | 44.84% | 274,265.3 | 176,453.4 | 476,787.5 | 464,378.3 | 312,553.7 | 311,557.5 | 790,622.6 | 685,647.5 | ... | ... | ... | ... |
| 311 | ទ្រព្យអចលត៍ | 7,787,594.1 | 2,730,640.7 | 35.06% | 274,265.3 | 163,255.2 | 427,778.5 | 410,684.2 | 255,094.8 | 257,529.7 | 500,550.3 | 441,482.7 | ... | ... | ... | ... |
| 314 | ទ្រព្យសកម្មគ្មានផលិតភាព | 4.0 | 761,625.1 | | 0.0 | 13,198.2 | 49,009.0 | 53,694.1 | 57,458.8 | 54,027.8 | 290,072.4 | 244,164.8 | ... | ... | ... | ... |
| ***2M*** | ***ចំណាយសរុប*** | 21,997,114.1 | 11,854,545.6 | 53.89% | 873,028.6 | 1,168,153.3 | 1,493,394.7 | 1,392,737.3 | 1,440,508.9 | 1,401,131.5 | 2,175,960.8 | 1,909,630.5 | 0.0 | 0.0 | 0.0 | 0.0 |
| ***NLB*** | ***សមតុល្យនៃការអោយខ្ចី/ប្រាក់កម្ចី*** | **-3,971,009.1** | **1,010,966.0** | **...** | **418,317.2** | **172,207.8** | **312,292.7** | **596,620.4** | **279,946.8** | **161,811.1** | **-705,170.8** | **-225,059.1** | **0.0** | **0.0** | **0.0** | **0.0** |
| **32** | **ទ្រព្យហិរញ្ញវត្ថុសុទ្ធ** | -180,193.0 | 1,603,514.2 | ... | 523,800.0 | 160,616.1 | 463,503.6 | 735,406.7 | 347,478.7 | 277,498.8 | -709,233.5 | -195,556.2 | 0.0 | 0.0 | 0.0 | 0.0 |
| 321 | ក្នុងប្រទេស | -180,193.0 | 1,603,514.2 | ... | 523,800.0 | 160,616.1 | 463,503.6 | 735,406.7 | 347,478.7 | 277,498.8 | -709,233.5 | -195,556.2 | 0.0 | 0.0 | 0.0 | 0.0 |
| **33** | **បំណុលសុទ្ធ** | 3,343,444.0 | 592,505.3 | 17.72% | 105,482.8 | -11,591.7 | 151,394.5 | 138,952.7 | 67,533.0 | 115,860.9 | -4,689.3 | 29,562.5 | 0.0 | 0.0 | 0.0 | 0.0 |
| 332 | ក្រៅប្រទេស | 3,343,444.0 | 592,505.3 | 17.72% | 105,482.8 | -11,591.7 | 151,394.5 | 138,952.7 | 67,533.0 | 115,860.9 | -4,689.3 | 29,562.5 | 0.0 | 0.0 | 0.0 | 0.0 |

ថ្ងៃ ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**អគ្គនាយក**

**អគ្គនាយកដ្ឋានគោលនយោបាយ**

ថ្ងៃ ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**ប្រធាននាយកដ្ឋានស្ដីទី**

**នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច**

ថ្ងៃ ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**ប្រធានការិយាល័យ**

**ស្ថិតិហិរញ្ញវត្ថុសាធារណ:**

# ២.២.តារាងស្ថិតិចំណូល

ឯកតា÷ លានរៀល

| | | ច្បាប់ឆ្នាំ ២០១៨ | អនុវត្តន៍ ២០១៨ | អនុ/ច្ប ២០១៨ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភៈ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីសាស្ត្រគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| **1** | **ចំណូល** | **18,026,105.0** | **12,865,511.6** | **71.37%** | **1,291,345.8** | **1,340,361.1** | **1,805,687.4** | **1,989,357.7** | **1,720,455.6** | **1,562,942.6** | **1,470,790.0** | **1,684,571.4** | **0.0** | **0.0** | **0.0** | **0.0** |
| **11** | **ពន្ធ** | **14,814,568.0** | **10,952,974.3** | **73.93%** | **1,120,259.9** | **1,140,239.1** | **1,653,275.1** | **1,604,796.2** | **1,423,042.7** | **1,360,855.9** | **1,178,491.5** | **1,472,013.8** | **0.0** | **0.0** | **0.0** | **0.0** |
| **111** | **ពន្ធលើប្រាក់ចំណូល និងប្រាក់ចំណេញ** | 3,899,306.0 | 2,804,216.9 | 71.92% | 234,797.6 | 176,185.1 | 567,838.3 | 667,474.9 | 365,263.0 | 246,744.0 | 259,192.3 | 286,721.8 | ... | ... | ... | ... |
| 1112 | ពន្ធនីតិបុគ្គល | 2,729,306.0 | 2,234,043.9 | 81.85% | 160,555.0 | 102,733.6 | 496,013.6 | 578,122.9 | 308,160.1 | 173,838.9 | 197,123.4 | 217,496.3 | ... | ... | ... | ... |
| **114** | **ពន្ធលើទំនិញ និងសេវាប្រើប្រាស់** | 8,786,262.0 | 6,641,283.0 | 75.59% | 728,076.7 | 793,204.1 | 897,916.4 | 760,327.1 | 849,373.4 | 926,014.6 | 746,130.8 | 940,240.0 | ... | ... | ... | ... |
| 1141 | ពន្ធទូទៅលើទំនិញ និងសេវាប្រើប្រាស់ | 4,812,262.0 | 3,444,818.2 | 71.58% | 373,205.4 | 360,245.0 | 462,475.6 | 393,804.1 | 446,354.5 | 523,427.6 | 409,281.3 | 476,024.6 | ... | ... | ... | ... |
| 11411 | អាករលើតម្លៃបន្ថែម | 4,812,262.0 | 3,444,610.3 | 71.58% | 373,204.2 | 360,244.9 | 462,469.5 | 393,637.0 | 446,354.4 | 523,414.4 | 409,281.3 | 476,004.7 | ... | ... | ... | ... |
| 11414 | ពន្ធលើប្រតិបត្តការហិរញ្ញវត្ថុ និងមូលធន | ... | 166.4 | ... | 0.0 | 0.0 | 0.0 | 166.4 | 0.0 | 0.0 | 0.0 | 0.0 | ... | ... | ... | ... |
| 1142 | អាករពិសេស | 3,974,000.0 | 3,196,464.8 | 80.43% | 354,871.3 | 432,959.1 | 435,440.8 | 366,522.9 | 403,018.9 | 402,586.9 | 336,849.5 | 464,215.3 | ... | ... | ... | ... |
| **115** | **ពន្ធលើពាណិជ្ជកម្មអន្តរជាតិ** | 2,120,500.0 | 1,498,750.3 | 70.68% | 157,283.6 | 170,393.1 | 185,349.7 | 174,557.3 | 208,046.8 | 187,040.5 | 171,294.6 | 244,784.6 | ... | ... | ... | ... |
| 1151 | អាករ និងបន្ទុកនាំចូលផ្សេងៗ | 2,075,200.0 | 1,466,620.3 | 70.67% | 149,823.1 | 166,600.8 | 182,123.7 | 172,186.7 | 204,334.1 | 184,042.8 | 167,275.8 | 240,233.2 | ... | ... | ... | ... |
| **116** | **ពន្ធផ្សេងៗ** | 8,500.0 | 8,724.2 | 102.64% | 102.0 | 456.7 | 2,170.7 | 2,436.9 | 359.5 | 1,056.9 | 1,873.8 | 267.5 | ... | ... | ... | ... |
| **13** | **អំណោយ** | **716,102.0** | **538,627.0** | **75.22%** | **49,258.5** | **49,258.5** | **58,224.8** | **72,131.9** | **150,755.6** | **60,270.6** | **49,258.5** | **49,468.6** | **...** | **...** | **...** | **...** |
| **131** | **អំណោយពីរដ្ឋាភិបាលអន្តរជាតិ** | 295,551.0 | 207,079.0 | 70.07% | 24,629.3 | 24,629.3 | 24,629.3 | 24,629.3 | 24,629.3 | 34,674.3 | 24,629.3 | 24,629.3 | ... | ... | ... | ... |
| 1311 | ចរន្ត | ... | 10,045.0 | ... | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 10,045.0 | 0.0 | 0.0 | ... | ... | ... | ... |
| 1312 | មូលធន | 295,551.0 | 197,034.0 | 66.67% | 24,629.3 | 24,629.3 | 24,629.3 | 24,629.3 | 24,629.3 | 24,629.3 | 24,629.3 | 24,629.3 | ... | ... | ... | ... |
| **132** | **អំណោយពីអង្គការអន្តរជាតិ** | 420,551.0 | 331,548.0 | 78.84% | 24,629.3 | 24,629.3 | 33,595.6 | 47,502.6 | 126,126.4 | 25,596.4 | 24,629.3 | 24,839.3 | ... | ... | ... | ... |
| 1321 | ចរន្ត | ... | 210.1 | ... | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 210.1 | ... | ... | ... | ... |
| 1322 | មូលធន | 420,551.0 | 331,337.9 | 78.79% | 24,629.3 | 24,629.3 | 33,595.6 | 47,502.6 | 126,126.4 | 25,596.4 | 24,629.3 | 24,629.3 | ... | ... | ... | ... |
| **14** | **ចំណូលផ្សេងៗ** | **2,495,435.0** | **1,373,910.3** | **55.06%** | **121,827.4** | **150,863.5** | **94,187.5** | **312,429.6** | **146,657.3** | **141,816.0** | **243,040.0** | **163,089.0** | **...** | **...** | **...** | **...** |
| **141** | **ចំណូលពីទ្រព្យសម្បត្តិ** | 197,844.5 | 222,284.4 | 112.35% | 4,637.0 | 2,751.2 | 9,075.6 | 146,132.0 | 10,622.5 | 9,932.2 | 17,871.5 | 21,262.4 | ... | ... | ... | ... |
| 1411 | ចំណូលការប្រាក់ | 82,526.0 | 69,998.2 | 84.82% | 0.0 | 0.0 | 7,116.6 | 26,332.5 | 2,193.4 | 7,250.9 | 13,670.8 | 13,433.9 | ... | ... | ... | ... |
| 14112 | ចំណូលការប្រាក់ក្នុងប្រទេស | 82,526.0 | 69,998.2 | 84.82% | 0.0 | 0.0 | 7,116.6 | 26,332.5 | 2,193.4 | 7,250.9 | 13,670.8 | 13,433.9 | ... | ... | ... | ... |
| 1412 | ចំណូលភាគលាភ | 19,450.0 | 97,035.3 | 498.90% | 0.0 | 0.0 | 0.0 | 97,035.3 | 0.0 | 0.0 | 0.0 | 0.0 | ... | ... | ... | ... |
| 1413 | ចំណូលផលទុននៃសេវាផ្គត់ផ្គង់ (អគ្គិសនី, ទឹក...) | 33.1 | 38.0 | 114.95% | 0.0 | 0.0 | 10.5 | 0.0 | 12.9 | 0.0 | 0.0 | 14.7 | ... | ... | ... | ... |
| 1415 | ចំណូលពីការជួល | 95,835.4 | 55,212.9 | 57.61% | 4,637.0 | 2,751.2 | 1,948.5 | 22,764.2 | 8,416.2 | 2,681.3 | 4,200.7 | 7,813.8 | ... | ... | ... | ... |
| **142** | **ចំណូលពីការលក់ទំនិញ និងសេវាកម្ម** | 2,026,307.7 | 1,031,968.0 | 50.93% | 112,296.6 | 135,813.0 | 74,096.7 | 157,316.0 | 125,879.7 | 95,014.8 | 213,064.6 | 118,486.7 | ... | ... | ... | ... |

# ២.២.តារាងស្ថិតិចំណូល

ឯកតា÷ លានរៀល

| | | ច្បាប់ឆ្នាំ ២០១៨ | អនុវត្តន៍ ២០១៨ | អនុ/ច្ប ២០១៨ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភះ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីសាស្រ្តគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| 1421 | ចំណូលពីការលក់ក្នុងទីផ្សារ | 556,997.0 | 197,482.3 | 35.45% | 348.7 | 17,813.5 | 11,483.0 | 24,446.5 | 36,899.0 | 49,326.0 | 11,648.6 | 45,517.0 | ... | ... | ... | ... |
| 1422 | ចំណូលសេវារដ្ឋបាល | 967,018.4 | 549,711.4 | 56.85% | 61,060.8 | 66,657.8 | 60,880.0 | 76,367.7 | 56,199.8 | 13,465.5 | 147,234.0 | 67,845.7 | ... | ... | ... | ... |
| 1423 | ចំណូលពីការលក់ ឬសកម្មភាពផ្សេងៗ (ទេសចរណ៍, វប្បធម៌...) | 502,292.3 | 284,774.3 | 56.69% | 50,887.0 | 51,341.7 | 1,733.7 | 56,501.8 | 32,780.9 | 32,223.3 | 54,182.0 | 5,124.0 | ... | ... | ... | ... |
| **143** | **ចំណូលបានពីការពិន័យ** | 146,549.8 | 87,367.3 | 59.62% | 4,664.2 | 12,091.7 | 8,003.1 | 8,613.8 | 9,566.2 | 9,845.9 | 11,618.2 | 22,964.1 | ... | ... | ... | ... |
| **144** | **ការផ្ទេរផ្សេងៗដែលមិនបានញែក** | 124,733.0 | 32,290.6 | 25.89% | 229.6 | 207.6 | 3,012.2 | 367.8 | 588.9 | 27,023.1 | 485.7 | 375.8 | ... | ... | ... | ... |
| 1441 | ចរន្ត | 124,733.0 | 32,290.6 | 25.89% | 229.6 | 207.6 | 3,012.2 | 367.8 | 588.9 | 27,023.1 | 485.7 | 375.8 | ... | ... | ... | ... |
| 14412 | ផ្សេងៗ | 124,733.0 | 32,290.6 | 25.89% | 229.6 | 207.6 | 3,012.2 | 367.8 | 588.9 | 27,023.1 | 485.7 | 375.8 | ... | ... | ... | ... |

# ២.៣.តារាងស្ថិតិចំណាយ

ឯកតា÷ លានរៀល

| | | ច្បាប់ឆ្នាំ ២០១៨ | អនុវត្តន៍ ២០១៨ | អនុ/ច្បា ២០១៨ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភៈ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីសាស្ត្រគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| **2** | **ចំណាយ** | **14,209,516.0** | **8,362,279.8** | **58.85%** | **598,763.3** | **991,699.9** | **1,016,607.3** | **928,359.0** | **1,127,955.2** | **1,089,574.0** | **1,385,338.2** | **1,223,983.0** | **...** | **...** | **...** | **...** |
| **21** | **បន្ទុកបុគ្គលិក** | **7,002,828.9** | **4,459,884.3** | **63.69%** | **457,742.4** | **499,001.0** | **567,747.9** | **531,646.2** | **570,046.3** | **605,655.7** | **647,725.3** | **580,319.5** | **...** | **...** | **...** | **...** |
| **211** | **ប្រាក់ខែ** | 7,002,828.9 | 4,459,884.3 | 63.69% | 457,742.4 | 499,001.0 | 567,747.9 | 531,646.2 | 570,046.3 | 605,655.7 | 647,725.3 | 580,319.5 | ... | ... | ... | ... |
| **22** | **ទំនិញ និងសេវាកម្ម** | **3,122,211.4** | **1,306,058.4** | **41.83%** | **42,110.0** | **39,564.2** | **78,300.7** | **133,807.8** | **224,856.7** | **170,519.7** | **288,392.1** | **328,507.2** | **...** | **...** | **...** | **...** |
| **24** | **ការប្រាក់** | **387,481.0** | **281,518.6** | **72.65%** | **26,400.5** | **57,738.6** | **57,697.5** | **11,758.8** | **13,953.2** | **3,081.8** | **27,096.6** | **83,791.6** | **...** | **...** | **...** | **...** |
| **242** | **បំណុលក្នុងស្រុកមិនមែនរដ្ឋាភិបាល** | 0.0 | 167.7 | ... | 0.0 | 0.0 | 0.0 | 0.0 | 167.7 | 0.0 | 0.0 | 0.0 | ... | ... | ... | ... |
| **25** | **ការឧបត្ថម្ភធន** | **10,920.0** | **10,484.7** | **96.01%** | **0.0** | **0.0** | **0.0** | **0.0** | **5,206.7** | **0.0** | **5,278.0** | **0.0** | **...** | **...** | **...** | **...** |
| **251** | **សហគ្រាសសាធារណៈ** | 10,920.0 | 10,484.7 | 96.01% | 0.0 | 0.0 | 0.0 | 0.0 | 5,206.7 | 0.0 | 5,278.0 | 0.0 | ... | ... | ... | ... |
| **26** | **អំណោយ** | **1,217,274.4** | **922,494.8** | **75.78%** | **991.9** | **298,149.7** | **52,122.5** | **174,505.9** | **50,276.2** | **32,773.3** | **203,541.7** | **110,133.7** | **...** | **...** | **...** | **...** |
| **262** | **អង្គការអន្តរជាតិ** | 162,847.3 | 49,822.0 | 30.59% | 112.8 | 6,496.9 | 4,310.5 | 8,836.5 | 13,270.5 | 4,241.9 | 5,957.6 | 6,595.3 | ... | ... | ... | ... |
| **263** | **រដ្ឋាភិបាលដទៃទៀត (រដ្ឋាបាលថ្នាក់ក្រោមជាតិ,...)** | 1,054,427.1 | 872,672.8 | 82.76% | 879.1 | 291,652.9 | 47,811.9 | 165,669.4 | 37,005.7 | 28,531.3 | 197,584.1 | 103,538.4 | ... | ... | ... | ... |
| 2631 | ចរន្ត | 1,054,427.1 | 872,672.8 | 82.76% | 879.1 | 291,652.9 | 47,811.9 | 165,669.4 | 37,005.7 | 28,531.3 | 197,584.1 | 103,538.4 | ... | ... | ... | ... |
| **271** | **អត្ថប្រយោជន៍សន្តិសុខសង្គម** | 1.2 | ... | ... | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | ... | ... | ... | ... |
| **272** | **អត្ថប្រយោជន៍ជំនួយសង្គម** | 488,098.4 | 314,352.9 | 64.40% | 749.9 | 782.6 | 27,808.9 | 5,347.8 | 138,346.2 | 64,619.4 | 70,107.6 | 6,590.3 | ... | ... | ... | ... |
| **28** | **ចំណាយផ្សេងៗ** | **984,589.8** | **432,006.6** | **43.88%** | **8,718.0** | **18,783.3** | **127,896.4** | **27,378.1** | **40,971.6** | **119,087.2** | **50,976.5** | **38,195.5** | **...** | **...** | **...** | **...** |
| **282** | **ការផ្ទេរផ្សេងៗដែលមិនបានបែងចែក** | 984,589.8 | 432,006.6 | 43.88% | 8,718.0 | 18,783.3 | 127,896.4 | 27,378.1 | 40,971.6 | 119,087.2 | 50,976.5 | 38,195.5 | ... | ... | ... | ... |
| 2821 | ចរន្ត | 984,589.8 | 432,006.6 | 43.88% | 8,718.0 | 18,783.3 | 127,896.4 | 27,378.1 | 40,971.6 | 119,087.2 | 50,976.5 | 38,195.5 | ... | ... | ... | ... |
| **283** | **បុព្វលាភធានារ៉ាប់រង, និងផ្សេងៗ** | 1,588.1 | 442.6 | 27.87% | 0.0 | 0.0 | 183.5 | 0.0 | 1.4 | 172.7 | 25.6 | 59.4 | ... | ... | ... | ... |
| 2831 | បុព្វលាភធានារ៉ាប់រងចរន្ត | 1,588.1 | 442.6 | 27.87% | 0.0 | 0.0 | 183.5 | 0.0 | 1.4 | 172.7 | 25.6 | 59.4 | ... | ... | ... | ... |
| 28311 | បុព្វលាភធានារ៉ាប់រង | 1,588.1 | 442.6 | 27.87% | 0.0 | 0.0 | 183.5 | 0.0 | 1.4 | 172.7 | 25.6 | 59.4 | ... | ... | ... | ... |

# ២.៤.តារាងស្ថិតិបម្រែបម្រួលទ្រព្យសកម្ម/បំណុល

ឯកតា÷ លានរៀល

| | | ច្បាប់ឆ្នាំ ២០១៨ | អនុវត្តន៍ ២០១៨ | អនុ/ច្ប ២០១៨ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភៈ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីសាស្ត្រគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| **3** | **បំរែបំរួលតម្លៃសុទ្ធនៃទ្រព្យកម្ម** | **4,263,961.1** | **4,503,274.7** | **105.61%** | **692,582.5** | **348,661.3** | **788,896.5** | **1,060,832.3** | **592,499.5** | **473,195.4** | **86,078.4** | **460,528.8** | **...** | **...** | **...** | **...** |
| **31** | **ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ** | **7,787,598.1** | **3,492,265.8** | **44.84%** | **274,265.3** | **176,453.4** | **476,787.5** | **464,378.3** | **312,553.7** | **311,557.5** | **790,622.6** | **685,647.5** | **...** | **...** | **...** | **...** |
| **311** | **អចលនទ្រព្យ** | 7,787,594.1 | 2,730,640.7 | 35.06% | 274,265.3 | 163,255.2 | 427,778.5 | 410,684.2 | 255,094.8 | 257,529.7 | 500,550.3 | 441,482.7 | ... | ... | ... | ... |
| **311B** | ***ការលក់÷ អចលនទ្រព្យ*** | 3.0 | ... | ... | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | ... | ... | ... | ... | ... |
| 3111 | អាគារ និងសំណង់ផ្សេងៗ | 7,472,736.0 | 2,505,960.0 | 33.53% | 161,363.0 | 163,188.6 | 421,332.7 | 396,728.8 | 238,827.5 | 246,988.8 | 449,337.4 | 428,193.2 | ... | ... | ... | ... |
| 3111A | *ការទិញ÷ អាគារ និងសំណង់ផ្សេងៗ* | 7,472,739.0 | 2,505,960.0 | 33.53% | 161,363.0 | 163,188.6 | 421,332.7 | 396,728.8 | 238,827.5 | 246,988.8 | 449,337.4 | 428,193.2 | ... | ... | ... | ... |
| 3111B | *ការលក់÷ អាគារ និងសំណង់ផ្សេងៗ* | 3.0 | ... | ... | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | ... | ... | ... | ... | ... |
| 3112 | ម៉ាស៊ីន និងសម្ភារបរិក្ខា | 314,858.1 | 224,680.7 | 71.36% | 112,902.2 | 66.6 | 6,445.8 | 13,955.4 | 16,267.4 | 10,540.9 | 51,212.8 | 13,289.6 | ... | ... | ... | ... |
| 3112A | *ការទិញ÷ ម៉ាស៊ីន និងសម្ភារបរិក្ខា* | 314,858.1 | 224,680.7 | 71.36% | 112,902.2 | 66.6 | 6,445.8 | 13,955.4 | 16,267.4 | 10,540.9 | 51,212.8 | 13,289.6 | ... | ... | ... | ... |
| **314A** | ***ការទិញ÷ ទ្រព្យសកម្មគ្មានផលិតភាព*** | 4.0 | 761,625.1 | | 0.0 | 13,198.2 | 49,009.0 | 53,694.1 | 57,458.8 | 54,027.8 | 290,072.4 | 244,164.8 | ... | ... | ... | ... |
| 3141 | ដី | 4.0 | 761,625.1 | | 0.0 | 13,198.2 | 49,009.0 | 53,694.1 | 57,458.8 | 54,027.8 | 290,072.4 | 244,164.8 | ... | ... | ... | ... |
| **32** | **ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ** | **-180,193.0** | **1,603,514.2** | **...** | **523,800.0** | **160,616.1** | **463,503.6** | **735,406.7** | **347,478.7** | **277,498.8** | **-709,233.5** | **-195,556.2** | **...** | **...** | **...** | **...** |
| 3202 | រូបិយប័ណ្ណ និងប្រាក់បញ្ញើ | 0.0 | 1,734,430.8 | ... | 523,800.0 | 160,616.1 | 476,387.0 | 766,017.0 | 347,478.7 | 304,185.5 | -670,785.6 | -173,268.0 | ... | ... | ... | ... |
| 3204 | កម្ចី | -180,193.0 | -99,214.7 | ... | 0.0 | 0.0 | -12,883.5 | -28,833.2 | 0.0 | -16,591.9 | -18,397.8 | -22,508.3 | ... | ... | ... | ... |
| 3205 | ដើមទុន និងមូលនិធិភាគហ៊ុន | 0.0 | -31,701.9 | ... | 0.0 | 0.0 | 0.0 | -1,777.0 | 0.0 | -10,094.9 | -20,050.0 | 220.0 | ... | ... | ... | ... |
| **321** | **ក្នុងស្រុក** | -180,193.0 | 1,603,514.2 | ... | 523,800.0 | 160,616.1 | 463,503.6 | 735,406.7 | 347,478.7 | 277,498.8 | -709,233.5 | -195,556.2 | ... | ... | ... | ... |
| 3212 | រូបិប័ណ្ណ និងប្រាក់បញ្ញើ | 0.0 | 1,734,430.8 | ... | 523,800.0 | 160,616.1 | 476,387.0 | 766,017.0 | 347,478.7 | 304,185.5 | -670,785.6 | -173,268.0 | ... | ... | ... | ... |
| 3214 | កម្ចី | -180,193.0 | -99,214.7 | ... | 0.0 | 0.0 | -12,883.5 | -28,833.2 | 0.0 | -16,591.9 | -18,397.8 | -22,508.3 | ... | ... | ... | ... |
| 3215 | ដើមទុន និងមូលនិធិភាគហ៊ុន | 0.0 | -31,701.9 | ... | 0.0 | 0.0 | 0.0 | -1,777.0 | 0.0 | -10,094.9 | -20,050.0 | 220.0 | ... | ... | ... | ... |
| **33** | **បំណុលសុទ្ធ** | **3,343,444.0** | **592,505.3** | **17.72%** | **105,482.8** | **-11,591.7** | **151,394.5** | **138,952.7** | **67,533.0** | **115,860.9** | **-4,689.3** | **29,562.5** | **...** | **...** | **...** | **...** |
| 3304 | កម្ចី | 3,343,444.0 | 592,505.3 | 17.72% | 105,482.8 | -11,591.7 | 151,394.5 | 138,952.7 | 67,533.0 | 115,860.9 | -4,689.3 | 29,562.5 | ... | ... | ... | ... |
| **332** | **ក្រៅស្រុក** | 3,343,444.0 | 592,505.3 | 17.72% | 105,482.8 | -11,591.7 | 151,394.5 | 138,952.7 | 67,533.0 | 115,860.9 | -4,689.3 | 29,562.5 | ... | ... | ... | ... |
| 3324 | កម្ចី | 3,343,444.0 | 592,505.3 | 17.72% | 105,482.8 | -11,591.7 | 151,394.5 | 138,952.7 | 67,533.0 | 115,860.9 | -4,689.3 | 29,562.5 | ... | ... | ... | ... |

# ៣. ក្រាហ្វិក


ក្រាហ្វិកទី ១៖ សូចនាករសំខាន់ៗនៃប្រតិបត្តិការរដ្ឋាភិបាល
ឯកតា៖ គិតជាប៊ីលានរៀល
3,000
2,000
1,000
0
-1,000
-2,000
-3,000
មករា
មេសា
កក្កដា
តុលា
ចំណូល(២០១៨)
ចំណាយ(២០១៨)
ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ(២០១៨)
ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ(២០១៨)
បំណុលសុទ្ធ(២០១៨)


ក្រាហ្វិកទី ២៖ ចំណូល (ពន្ធ អំណោយ និងផ្សេងៗ)
ឯកតា៖ គិតជាប៊ីលានរៀល
2,500
2,000
1,500
1,000
500
0
មករា
មេសា
កក្កដា
តុលា
ចំណូលពន្ធ ២០១៨
អំណោយ ២០១៨
ចំណូលផ្សេងៗ ២០១៨
ចំណូលពន្ធ ២០១៧
ចំណូលអំណោយ ២០១៧
ចំណូលផ្សេងៗ ២០១៧


ក្រាហ្វិកទី ៣៖ ចំណូលពន្ធ
ឯកតា៖ គិតជាប៊ីលានរៀល
1,000
800
600
400
200
0
មករា
មេសា
កក្កដា
តុលា
ពន្ធលើប្រាក់ចំណូលនិងប្រាក់ចំណេញ ២០១៨
ពន្ធលើទំនិញ និងសេវាប្រើប្រាស់ ២០១៨
ពន្ធលើពាណិជ្ជកម្មអន្តរជាតិ ២០១៨
ពន្ធលើប្រាក់ចំណូល និងប្រាក់ចំណេញ ២០១៧
ពន្ធលើទំនិញ និងទំនិញប្រើប្រាស់ ២០១៧
ពន្ធលើពាណិជ្ជកម្មអន្តរជាតិ ២០១៧


ក្រាហ្វិកទី ៤៖ ចំណាយសរុប
ឯកតា៖ គិតជាប៊ីលានរៀល
1,600
1,400
1,200
1,000
800
600
400
200
0
មករា
មេសា
កក្កដា
តុលា
ចំណាយ ២០១៨
ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ២០១៨
ចំណាយ ២០១៧
ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ២០១៧

# ៣. ក្រាហ្វិក


ក្រាហ្វិកទី ៥÷ ចំណាយ
ឯកតា÷ ពាន់លានរៀល
800
700
600
500
400
300
200
100
0
មករា
មេសា
កក្កដា
តុលា
ចំណាយបន្ទុកបុគ្គលិក ២០១៨
ចំណាយមិនមែនបន្ទុកបុគ្គលិក ២០១៨
ចំណាយបន្ទុកបុគ្គលិក ២០១៧
ចំណាយមិនមែនបន្ទុកបុគ្គលិក ២០១៧


ក្រាហ្វិកទី ៦÷ ប្រតិបត្តិការទ្រព្យសកម្ម និងបំណុល
ឯកតា÷ ពាន់លានរៀល
1,000
500
0
-500
-1,000
មករា
មេសា
កក្កដា
តុលា
ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ ២០១៨
ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ ២០១៨
បំណុលសុទ្ធ ២០១៨
ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ ២០១៧
ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ ២០១៧
បំណុលសុទ្ធ ២០១៧


ក្រាហ្វិកទី ៧÷ ទ្រព្យសកម្មហិរញ្ញវត្ថុ
ឯកតា÷ ពាន់លានរៀល
1,000
800
600
400
200
0
-200
-400
-600
-800
មករា
មេសា
កក្កដា
តុលា
រូបិយប័ណ្ណ និងប្រាក់បញ្ញើ ២០១៨
មិនមែនរូបិយប័ណ្ណ និងប្រាក់បញ្ញើ ២០១៨
រូបិយប័ណ្ណ និងប្រាក់បញ្ញើ ២០១៧
មិនមែនរូបិយប័ណ្ណ និងប្រាក់បញ្ញើ ២០១៧


ក្រាហ្វិកទី ៨÷ បំណុល
ឯកតា÷ ពាន់លានរៀល
400
300
200
100
0
-100
-200
-300
-400
-500
មករា
មេសា
កក្កដា
តុលា
កម្ចី ២០១៨
មិនមែនកម្ចី ២០១៨
កម្ចី ២០១៧
មិនមែនកម្ចី ២០១៧

# ៤.ខ្ទបសម្ព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលថ្នាក់ក្រោមជាតិ

ឯកតា÷ លានរៀល

| | | អនុវត្តន៍ ២០១៥ | អនុវត្តន៍ ២០១៦ | អនុវត្តន៍ ២០១៧ | អនុវត្តន៍ ឆមាសទី១ ឆ្នាំ២០១៨ |
|---|---|---|---|---|---|
| | វិធីសាស្ត្រគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash |
| **1** | **ចំណូល** | **1,449,977.4** | **1,444,774.2** | **1,798,487.9** | **981,894.9** |
| 11 | ពន្ធ | 761,372.3 | 755,258.1 | 1,009,595.3 | 510,434.8 |
| 12 | ការចូលរួមពីសង្គម | … | … | … | 0.0 |
| 13 | អំណោយ | 634,297.1 | 635,351.4 | 747,368.7 | 454,805.5 |
| 14 | ចំណូលផ្សេងៗ | 54,308.0 | 54,164.7 | 41,523.9 | 16,654.6 |
| **2** | **ចំណាយ** | **974,628.8** | **1,078,847.2** | **1,385,663.6** | **413,625.6** |
| 21 | បន្ទុកបុគ្គលិក | 225,075.1 | 308,999.5 | 332,644.7 | 180,899.8 |
| 22 | ទំនិញ និងសេវាកម្ម | 684,972.7 | 696,590.9 | 830,433.0 | 169,305.1 |
| 23 | ការប្រើប្រាស់ទុនអចល័ត | … | … | … | 0.0 |
| 24 | ការប្រាក់ | … | … | … | 0.0 |
| 25 | ឧបត្ថម្ភកធន | … | … | … | 0.0 |
| 26 | អំណោយ | 42.1 | 42.9 | 130,509.4 | 15,288.2 |
| 27 | ឧបត្ថម្ភសង្គមកិច្ច | 9,708.6 | 11,504.4 | 16,043.6 | 6,813.7 |
| 28 | ចំណាយផ្សេងៗ | 54,830.4 | 61,709.5 | 76,032.8 | 41,318.7 |
| ***GOB*** | ***តុល្យភាពប្រតិបត្តិការដុល*** | **475,348.6** | **365,927.1** | **412,824.3** | **568,269.3** |
| ***NOB*** | ***តុល្យភាពប្រតិបត្តិការសុទ្ធ*** | **475,348.6** | **365,927.1** | **412,824.3** | **568,269.3** |
| | **ប្រតិបត្តិការទ្រព្យមិនមែនហិរញ្ញវត្ថុ** | | | | 0.0 |
| **31** | **ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ** | 313,219.4 | 294,622.4 | 305,047.1 | 128,091.0 |
| 311 | ទ្រព្យអចល័ត | 311,694.1 | 276,672.4 | 305,007.7 | 127,859.8 |
| 312 | បម្រែបម្រួលសន្និធិ | … | … | … | 0.0 |
| 313 | វត្ថុមានតម្លៃ | … | … | … | 0.0 |
| 314 | ទ្រព្យសកម្មគ្មានផលិតភាព | 1,525.3 | 17,950.0 | 39.4 | 231.2 |
| ***2M*** | ***ចំណាយសរុប*** | 1,287,848.2 | 1,373,469.6 | 107,777.2 | 541,716.6 |
| ***NLB*** | ***សមតុល្យនៃការអោយខ្ចី/ប្រាក់កម្ចី*** | **162,129.2** | **71,304.7** | **107,777.2** | **440,178.3** |
| | **ប្រតិបត្តិការទ្រព្យហិរញ្ញវត្ថុ និង បំណុល (ហិរញ្ញប្បទាន)** | | | | 0.0 |
| **32** | **ទ្រព្យហិរញ្ញវត្ថុសុទ្ធ** | 271,748.2 | 52,119.5 | 227,152.6 | 208,324.0 |
| 321 | ក្នុងប្រទេស | 271,748.2 | 52,119.5 | 227,152.6 | 208,324.0 |
| 322 | ក្រៅប្រទេស | … | … | … | 0.0 |
| **33** | **បំណុលសុទ្ធ** | 109,619.0 | -19,183.6 | 121,270.8 | -208,558.9 |
| 331 | ក្នុងប្រទេស | 109,619.0 | -19,183.6 | 121,270.8 | -208,558.9 |
| 332 | ក្រៅប្រទេស | … | … | … | 0.0 |

## ៤.សេចក្តីសង្ខេបស្តីអំពី "ក្របខ័ណ្ឌស្តង់ដារស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល"

## អនុលោមទៅតាម Government Finance Statistics (GFSM2014)

### 1. របាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល

1.1. **របាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល** ជារបាយការណ៍មួយដែលបង្ហាញយ៉ាងលម្អិតតាមរយៈប្រតិបត្តិការសំខាន់ៗ ដូចជា÷ ចំណូល, ចំណាយ, វិនិយោគសុទ្ធលើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ, វិនិយោគសុទ្ធលើទ្រព្យសកម្មហិរញ្ញវត្ថុ, និងបំណុលសុទ្ធ។ ផ្អែកលើក្របខ័ណ្ឌស្តង់ដារស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលនេះ **ចំណូល** គឺជាប្រតិបត្តិការ (transaction) ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យកម្ម (net worth) កើនឡើង។ រីឯ**ចំណាយ** គឺជាប្រតិបត្តិការ (transactions) ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យកម្មថយចុះ។ **ការវិនិយោគសុទ្ធលើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ**គឺជាលទ្ធផលនៃអចលនទ្រព្យ (fixed assets) បូកសន្និធិសុទ្ធ, ទ្រព្យមានតម្លៃសុទ្ធ និងទ្រព្យគ្មានផលិតភាពសុទ្ធ (non-produce assets) ។

1.2. នៅក្នុងរបាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាលមានតុល្យភាពចំនួន ០២ ដែលជាធាតុដ៏សំខាន់ក្នុងកិច្ចការវិភាគ។ តុល្យភាពទី១ គឺជាផលសងនៃចំណូល និងចំណាយ ដែលហៅថា **តុល្យភាពប្រតិបត្តិការសុទ្ធ** និងតុល្យភាពទី២ គឺជាផលសងនៃតុល្យភាពប្រតិបត្តិការសុទ្ធ និងការវិនិយោគលើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ ដែលហៅថា **តុល្យភាពការឱ្យខ្ចី/ប្រាក់កម្ចីសុទ្ធ**។ តុល្យភាពទី២នេះ ក៏អាចបង្ហាញតាមរយៈផលសងនៃការវិនិយោគសុទ្ធលើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលសុទ្ធ។

1.3. **តុល្យភាពប្រតិបត្តិការសុទ្ធ** ទិន្នន័យតុល្យភាពនេះអាចយកទៅប្រៀបធៀបជាមួយគណនីជាតិតាមរយៈការបូកបញ្ចូលគ្នានៃការសន្សំនិងមូលនិធិផ្ទេរដែលត្រូវទទួល។ **តុល្យភាពប្រតិបត្តិការសុទ្ធ**នៅទីនេះមិនបានរាប់បញ្ចូលចំណេញ ឬខាតដែលកើតចេញពី ការប្រែប្រួលថ្លៃ (change in price level) និងការប្រែប្រួលជាបរិមាណ (other change in the volume)ទ្រព្យសកម្ម ឬបំណុលឡើយ។ គោលនយោបាយរបស់ រដ្ឋាភិបាលមានឥទ្ធិពលផ្ទាល់លើប្រតិបត្តិការដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យប្រែប្រួលព្រោះតែរដ្ឋាភិបាលជាអ្នកគ្រប់គ្រងដោយផ្ទាល់លើសេចក្តីសម្រេចចិត្តចំពោះគ្រប់ប្រតិបត្តិការទាំងអស់។ ចំណេញ ឬខាតចេញពីការប្រែប្រួលតម្លៃសុទ្ធនៃទ្រព្យសកម្ម ឬបំណុល(ប្រែប្រួលថ្លៃទីផ្សារ)និងការប្រែប្រួលជាបរិមាណ (ដោយសារព្រឹត្តិការណ៍ណាមួយ) គឺមិនស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋាភិបាលឡើយ តែរដ្ឋាភិបាលអាចមានយន្តការ ឬគោលនយោបាយដើម្បីកាត់បន្ថយផលប៉ះពាល់ដែលកើតចេញពីការប្រែប្រួលខាងលើឱ្យស្ថិតក្នុងកម្រិតអប្បរមា។

1.4. **តុល្យភាពការឱ្យខ្ចី/ប្រាក់កម្ចីសុទ្ធ** ដែលបង្ហាញឱ្យឃើញពីការប្រើប្រាស់ (វិនិយោគ) ធនធានហិរញ្ញវត្ថុទៅវិស័យខាងក្រៅទាំងសេដ្ឋកិច្ចក្នុងប្រទេស ឬក្រៅប្រទេស (ការឱ្យខ្ចី) ឬបង្ហាញឱ្យឃើញពីការទាញយកអត្ថប្រយោជន៍ប្រភពហិរញ្ញប្បទាន

ពីវិស័យខាងក្រៅទាំងសេដ្ឋកិច្ចក្នុងប្រទេស ឬក្រៅប្រទេស (ប្រាក់កម្ចី)។ តុល្យភាពនេះជាសូចនាករមួយដែលបង្ហាញឱ្យឃើញពីឥទ្ធិពលនៃសកម្មភាពហិរញ្ញវត្ថុរបស់រដ្ឋាភិបាលទៅលើសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រទេស។

**1.5. តុល្យភាពប្រតិបត្តិការដុល÷** មានភាពខុសគ្នាពីតុល្យភាពប្រតិបត្តិការសុទ្ធនៅត្រង់ថាតុល្យភាពប្រតិបត្តិការដុលមិនបានរួមបញ្ចូលនូវចំណាយលើការប្រើប្រាស់(រំលោះ)ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុឡើយ។ ចំណាយលើការប្រើប្រាស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុមានភាពលំបាកក្នុងការវាយតម្លៃ។ ប្រសិនបើតុល្យភាពប្រតិបត្តិការដុលធំជាងតុល្យភាពប្រតិបត្តិការសុទ្ធនេះមានន័យថាចំណាយលើការប្រើប្រាស់លើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុត្រូវបានកត់ត្រា។

**1.6. ចំណាយសរុប** (expenditure) គឺជាលទ្ធផលដែលបានមកពីចំណាយ (expenses) និងវិនិយោគ (ការទិញ/ដោះដូរ)លើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ។ ចំណាយសរុបនេះបានរួមបញ្ចូលទាំងចំណាយលើការប្រើប្រាស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុមានភាពសមស្របសម្រាប់ការប្រៀបធៀបជាមួយបណ្តាប្រទេសផ្សេងៗ បើទោះបីជាការវាយតម្លៃចំណាយរំលោះនៅមិនទាន់មានសង្គតិភាពនៅឡើយក៏ដោយ។

**1.7. ចំណូល** គឺជាប្រតិបត្តិការ (transaction) ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យកើនឡើង។ ធាតុសំខាន់ៗនៃចំណូលរួមមាន÷ ចំណូលពន្ធ (១១), ចំណូលពីការចូលរួមសង្គម (១២), ចំណូលពីអំណោយ (១៣), និងចំណូលផ្សេងៗ (១៤) ។ ចំណូលដែលបានមកពីការលក់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលប្រើប្រាស់រួច (ជម្រះបញ្ជី) មិនត្រូវបានទទួលស្គាល់ជាចំណូលឡើយ ពីព្រោះវាមិនបានធ្វើឱ្យមានការប្រែប្រួលតម្លៃសុទ្ធនៃទ្រព្យសកម្មនោះទេ។ អ្វីដែលប្រែប្រួលចេញពីប្រតិបត្តិការនេះគឺ ការប្រែប្រួលសមាសធាតុដែលមាននៅក្នុងតារាងតុល្យភាពតែប៉ុណ្ណោះ ពោលគឺទ្រព្យសកម្មមួយថយចុះ (ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ)ហើយ ទ្រព្យសកម្មផ្សេងកើនឡើង (សាច់ប្រាក់)។ ដូចគ្នាដែរសម្រាប់ប្រាក់កម្ចីដែលទទួលបានឬការសងបំណុលដែលគេជំពាក់ ក៏មិនត្រូវបានចាត់ទុកជាចំណូលដែរ។

**1.8. ចំណាយ** គឺជាប្រតិបត្តិការ (transaction)ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យថយចុះ។ ធាតុសំខាន់ៗនៃចំណាយ រួមមាន÷ ចំណាយប្រាក់បៀវត្ស និងលាភការ (២១), ចំណាយការប្រើប្រាស់ទំនិញ និងសេវាកម្ម (២២), ចំណាយលើការប្រាក់ (២៤) ,ចំណាយលើការឧបត្ថម្ភធន (២៥), ចំណាយលើអំណោយ (២៦) ចំណាយលើឧបត្ថម្ភសង្គមកិច្ច (២៧), និងចំណាយផ្សេងៗ(២៨)។ មិនត្រឹមតែប៉ុណ្ណោះ ចំណាយក៏ត្រូវបានធ្វើចំណាត់ថ្នាក់ ទៅតាមមុខងាររបស់រដ្ឋាភិបាលផងដែរ ដូចជា÷ ចំណាយលើសុខភាព ឬកិច្ចការពារសង្គមជាដើម។ ការទិញ ឬដោះដូរទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ មិនត្រូវបានចាត់ទុកជាចំណាយឡើយ ពីព្រោះវាមិនបានធ្វើឱ្យមានការប្រែប្រួលតម្លៃសុទ្ធនៃទ្រព្យឡើយ។ ការប្រែប្រួលកើតចេញពីប្រតិបត្តិការខាងលើនេះគឺ ការប្រែប្រួលសមាសធាតុដែលមាននៅក្នុងតារាងតុល្យភាពតែប៉ុណ្ណោះ។ ដូចគ្នាដែរសម្រាប់ប្រាក់កម្ចីដែលបានសង ក៏មិនត្រូវបានចាត់ទុកជាចំណាយដែរ។

**1.9.** ផ្នែកទីពានៃរបាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាលនេះ គឺជា**ប្រតិបត្តិការហិរញ្ញវត្ថុ** ទាំងឡាយដែលធ្វើឱ្យមានបម្រែបម្រួលទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុល។ ប្រតិបត្តិការហិរញ្ញវត្ថុត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកលើដៃគូ (counterpart) ដែលបានជំពាក់ (ទាំងក្នុង និងក្រៅប្រទេស) ទាំងក្នុងទ្រព្យសកម្ម និងបំណុល។

**1.10.** បន្ថែមលើចំណាត់ថ្នាក់ខាងលើ ប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលក៏ត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកលើប្រភេទឧបករណ៍ហិរញ្ញវត្ថុដែលមានដូចជា÷ រូបិយវត្ថុ មាស និងអេសឌីអា, រូបិយប័ណ្ណ និងប្រាក់បញ្ញើ, មូលបត្របំណុល, កម្ចី, ដើមទុន និងមូលនិធិភាគហ៊ុន, ធានារ៉ាប់រង សោធន និងកញ្ចប់ធានារ៉ាប់រង, ដេរីវេទីវហិរញ្ញវត្ថុ និងភាគហ៊ុនបុគ្គលិក, គណនីត្រូវទទួល/ត្រូវសងផ្សេងៗ។ មិនត្រឹមតែប៉ុណ្ណោះប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលក៏ត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកលើវិស័យដែលជាដៃគូបដិភាគនៃឧបករណ៍ហិរញ្ញវត្ថុដូចជា÷ សាជីវកម្មហិរញ្ញវត្ថុ, សាជីវកម្មមិនមែនហិរញ្ញវត្ថុ, គេហកិច្ច (household) និងស្ថាប័នមិនស្វែងរកប្រាក់ចំណេញ។

**1.11.** មធ្យោបាយម្យ៉ាងទៀត នៃការធ្វើចំណាត់ថ្នាក់ប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុល គឺដោយផ្អែកលើការកើនឡើងថ្មី ឬក៏ការជម្រះចេញ ដែលបម្រើឱ្យគោលដៅនយោបាយ ឬក៏ផ្អែកលើការគ្រប់គ្រងសន្ទនីភាព។ ភាពខុសគ្នានោះនៅត្រង់ថាវាមិនត្រូវបានរាប់បញ្ចូលក្នុងរបាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាលទេ តែវាត្រូវប្រើសម្រាប់កំណត់តុល្យភាពសារពើពន្ធ។

**1.12.** គោលនយោបាយសាធារណៈដែលទាក់ទងទៅនឹងទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលអាចត្រូវបានលើកមកគិតគូរក្នុងហេតុផលផ្សេងៗ ដូចជាការជម្រុញឧស្សាហកម្មថ្មី, ជួយសង្គ្រោះសាជីវកម្មសាធារណៈ, ឬក៏ជួយអាជីកម្មណាមួយដើម្បីឱ្យមានភាពសម្បូរបែបក្នុងសេដ្ឋកិច្ច។ ប្រតិបត្តិការទាំងនេះអាចមានទម្រង់ផ្សេងៗគ្នាដូចជា÷ កម្ចី, មូលបត្រដើមទុន ឬមូលបត្របំណុលជាដើម។ ជាមួយគ្នានេះដែរ ប្រតិបត្តិការខាងលើក៏អាចមានផងដែរក្នុងទម្រង់ជាសម្បទាន។

**1.13.** ប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗទៀត គឺត្រូវបានសន្មត់ថាជាការគ្រប់គ្រងសន្ទនីភាពឬក៏គោលបំណងផ្សេង។ ដែលនេះបង្ហាញថាទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានគ្រប់គ្រងដោយបានទាញយកផលប្រយោជន៍ស្របតាមអត្រាទីផ្សារ ព្រមទាំងធានាបាននូវមូលនិធិគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃ ឬគ្រប់គ្រាន់ជាមួយតម្រូវការសង្គមនៅពេលខាងមុខដូចជាមូលនិធិពិសេសរបស់រដ្ឋាភិបាលជាដើម។